ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខ: ០១៥៣.១៤.អផ.សសរ

# សេចក្តីសម្រេច
## ស្តីពីការបង្កើតក្រុមការងារចុះត្រួតពិនិត្យ និងអធិការកិច្ច
## សកម្មភាពសិក្សាស្រាវជ្រាវ និងអាជីវកម្មរ៉ែ និងរ៉ែសំណង់

## រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការបង្កើតក្រសួងរ៉ែ និងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និង បំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០១/០៩ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគ្រប់គ្រង និងធ្វើអាជីវកម្មធនធានរ៉ែ
- បានឃើញអនុក្រឹត្យលេខ ៥៧៦ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងរ៉ែ និងថាមពល
- យោងតាមការចាំបាច់របស់ក្រសួងរ៉ែ និងថាមពល

## <u>សម្រេច</u>

**ប្រការ១៖** បង្កើតក្រុមការងារ ដើម្បីចុះត្រួតពិនិត្យ និងអធិការកិច្ចសកម្មភាពសិក្សាស្រាវជ្រាវ និងអាជីវកម្មរ៉ែ និងរ៉ែសំណង់ ដូចខាងក្រោម៖

<u>ក្រុមទី១</u> ទទួលបន្ទុកខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ ខេត្តមណ្ឌលគិរី ខេត្តក្រចេះ ខេត្តរតនគិរី និងខេត្តស្ទឹងត្រែង។

| | | |
|---|---|---|
| ១- | ឯកឧត្តម ម៉េង សក្តិធារ៉ា | ប្រធាន |
| ២- | ឯកឧត្តម សុខ ឡេង | អនុប្រធាន |
| ៣- | លោក ជ្រា វិចិត្រ | សមាជិក |

៤- លោក នួន នរិន្ទ សមាជិក
៥- លោក ហ៊ីង ទន់ សមាជិក
៦- លោក សំ ស៊ីដារ៉ា សមាជិក
៧- លោក ហ៊ីង សារឿន សមាជិក
៨- លោក សេង យូហៃ សមាជិក
៩- លោក គង់ ស៊ីថា សមាជិក

**ក្រុមទី II** ទទួលបន្ទុកខេត្តកំពង់ធំ ខេត្តព្រះវិហារ ខេត្តសៀមរាប ខេត្តឧត្តរមានជ័យ ខេត្តបន្ទាយមានជ័យ ខេត្តប៉ៃលិន ខេត្តបាត់ដំបង ខេត្តពោធិ៍សាត់ និងខេត្តកំពង់ឆ្នាំង។

១- ឯកឧត្តម ហូ វិចិត្រ ប្រធាន
២- ឯកឧត្តម ញ៉ឹក សុមេធ អនុប្រធាន
៣- ឯកឧត្តម យស មុនីរ៉ាត់ សមាជិក
៤- លោក ទៀង សុខុម សមាជិក
៥- លោក ម៉ក់ សុភក្ត្រា សមាជិក
៦- លោក សេង លាំង សមាជិក
៧- លោក អ៊ុយ រិទ្ធ សមាជិក
៨- លោក យិន រតនៈ សមាជិក
៩- លោក លឹម បញ្ញា សមាជិក

**ក្រុមទី III** ទទួលបន្ទុកខេត្តកំពង់ស្ពឺ ខេត្តកំពត ខេត្តកែប ខេត្តកោះកុង ខេត្តព្រះសីហនុ ខេត្តតាកែវ ខេត្តស្វាយរៀង ខេត្តព្រៃវែង រាជធានីភ្នំពេញ និងខេត្តកណ្តាល។

១- ឯកឧត្តម ឌិត ទីណា ប្រធាន
២- ឯកឧត្តម ហេង ចាន់ធួន អនុប្រធាន
៣- លោក ប៉េង ណាវុធ សមាជិក
៤- លោក សៀង សុថាម សមាជិក
៥- លោក ហុង បូណា សមាជិក
៦- លោក ឡាយ ហប្រានីត សមាជិក
៧- លោក នី ផារ័ត្ន សមាជិក
៨- លោក ស៊ូ ភីរៈ សមាជិក
៩- លោក ខូវ សុវណ្ណរតនា សមាជិក

**ប្រការ២៖** ក្រុមការងារខាងលើមានភារកិច្ច៖

- ចុះពិនិត្យដល់ទីកន្លែងនូវសកម្មភាពសិក្សាស្រាវជ្រាវ / អាជីវកម្មរបស់ក្រុមហ៊ុន ដែលទទួលបានអាជ្ញាបណ្ណស្វែងរុករក / អាជីវកម្ម និងអាជ្ញាបណ្ណអាជ្ញាធរមីន និងការដ្ឋានវាយថ្មទៅតាមបណ្តារាជធានី ខេត្ត។

- វាយតម្លៃសកម្មភាពសិក្សាស្រាវជ្រាវ / អាជីវកម្មដោយផ្អែកទៅលើកម្មវិធីការងារ និងថវិកាដែលលើកស្នើមកក្រសួង។
- ពិនិត្យគម្រោងផែនការអភិវឌ្ឍសង្គម(CSR)របស់ក្រុមហ៊ុននិមួយៗ។
- ពិនិត្យប្រក្រតីភាពនៃការអនុវត្តគម្រោងនីមួយៗ។
- ពិនិត្យភាពអនុលោម ផ្អែកទៅតាមច្បាប់ និងកិច្ចព្រមព្រៀងដែលមានជាមួយក្រសួងរ៉ែ និងថាមពល។

**ប្រការ៣៖** ក្រុមការងារទាំង០៣ខាងលើ ត្រូវបញ្ចប់ការងាររបស់ខ្លួនមុនថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ហើយធ្វើរបាយការណ៍សរុបជូនក្រសួងពិនិត្យ និងវាយតម្លៃការងារបច្ចេកទេស ការការពារបរិស្ថាន និងភាពអនុលោមទាំងឡាយផ្សេងទៀត ដើម្បីសម្រេចចាត់វិធានការបន្ត។

**ប្រការ៤៖** នាយកខុទ្ទកាល័យ អគ្គនាយកកិច្ចការទូទៅ អគ្គនាយកធនធានរ៉ែ អគ្គាធិការ និងអង្គភាពពាក់ព័ន្ធ ត្រូវអនុវត្តតាមសេចក្តីសម្រេចនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែមករា ឆ្នាំ២០១៥

រដ្ឋមន្ត្រី

ស៊ុយ សែម